**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**លេខ...០២/១៧..នព**

## សេចក្តីប្រកាសព័ត៌មាន
## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

អ្នកនាំពាក្យក្រសួងការពារជាតិ សូមជម្រាបសាធារណៈជនជ្រាបនូវព័ត៌មានស្តីពី កងកម្លាំងវិស្វកម្មកម្ពុជាម្នាក់បានពលី ម្នាក់រងរបួស និងបីនាក់ទៀតបាត់ខ្លួនក្នុងពេលកំពុងបំពេញបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ នៅសាធារណៈរដ្ឋអាប្រ្វិកកណ្តាលដែលក្នុងនោះរួមមាន៖

១.លោកពលបាលឯក អ៊ឹម សំ បុគ្គលិកបើកបរប៊ុលដូស៊ែរ(ស្លាប់)

២.លោកពលបាលឯក ធុច ធីម បុគ្គលិកបើកបររថយន្តបែន(រងរបួសដៃឆ្វេង)

៣.លោកអនុសេនីយ៍ត្រីស៊ាង នរិន្ទ ជំនួយការត្រួតពិនិត្យគុណភាព(បាត់ខ្លួន)

៤.លោកពលបាលឯក មុំ តុលា ជំនួយការបើកបរអិចស្កាវ៉ាទ័រ(បាត់ខ្លួន)

៥.លោកអនុសេនីយ៍ត្រី ម៉ៅ អេង បុគ្គលិកពេទ្យ(បាត់ខ្លួន)

ឧបត្តវហេតុនេះកើតឡើងនៅថ្ងៃទី ០៨ខែឧសភាឆ្នាំ២០១៧ នៅពេលដែលកងកម្លាំងវិស្វកម្មកម្ពុជា មួយក្រុមមានសមាជិក១២នាក់ ការពារដោយកម្លាំងប្រទេស ម៉ារ៉ុក បានវិលត្រឡប់ពីបំពេញភារកិច្ចក្នុងតំបន់(Rafai)លុះមកដល់វេលាម៉ោង៨:០០នាទីយប់ (ត្រូវនឹងម៉ោង២ទៀបភ្លឺថ្ងៃទី០៩ខែឧសភាឆ្នាំ២០១៧ នៅភ្នំពេញ) ក្នុងភូមិ (Yogofongo) ដែលមានចំងាយប្រមាណ ២0km ខាងកើតតំបន់ (Bangassou) មានការពួនស្ទាក់បាញ់ប្រហារមកលើក្បួនយុទ្ធដំណើររបស់កម្លាំង MINUSCA ដោយក្រុមប្រដាប់អាវុធមិនស្គាល់អត្តសញ្ញាណ បណ្តាលអោយកម្លាំងកម្ពុជាស្លាប់ម្នាក់ របួសម្នាក់និងបីនាក់ទៀតបាត់ខ្លួន។

ក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែងនូវការសោកស្តាយជាអនេកប្បកានិងចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំចំពោះការពលីជីវិតប្រកបដោយកិត្តិយសថ្លៃថ្នូរ និងវិរភាពដ៏អង់អាចក្លាហាននៃកុលបុត្រកម្ពុជា ដែលបានលះបង់ជីវិតក្នុងការបំពេញបេសកកម្មមនុស្សធម៌អន្តរជាតិក្រោមឆ័ត្រអ.ស.ប.នៅសាធារណៈរដ្ឋអាហ្វ្រិចកណ្តាល។ក្រសួងការពារជាតិកំពុងសហប្រតិបត្តិការជាមួយអ.ស.ប.ក្នុងកិច្ចប្រឹងស្វែងរកយទ្ធជនកម្ពុជាដែលនៅកំពុងបាត់ខ្លួនបីនាក់ទៀត៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ខែឧសភា ឆ្នាំ ២០១៧*

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ c@mod.gov.kh